00401579

FR/D/N: D237

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 11 / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០០៩

ឯកសារដែលបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស: សម្ងាត់ CONFIDENTIAL CONFIDENTIEL

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន: សាធារណៈ PUBL[IC] 13/11/2009

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

13/01/2010

---

**មេធាវីការពារក្តី ស្នើសុំឲ្យបន្ថែមពេលវេលានៅពេលបញ្ចប់ការស៊ើបសួរ**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅសឹង

កញ្ញា Diana ELLIS QC

**មេធាវីការពារក្តីរបស់ជនត្រូវចោទផ្សេងទៀត**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណីគ្មានតំណាង**

<u>ផ្ញើជូន៖</u>

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក William SMITH

## I. សេចក្តីផ្តើម និង ការស្នើសុំ

១. ជាច្រើនលើកច្រើនសារកាលពីប៉ុន្មានខែចុងក្រោយនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត (កសចស)បានចង្អុលបង្ហាញថាខ្លួនមានបំណងជូនដំណឹងដល់គ្រប់ភាគីអំពីការបញ្ចប់ការស៊ើបសួរ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៦៦ (១) (វិធាន ៦៦ ស្តីពីការជូនដំណឹង) នៅក្នុងខែធ្នូឆ្នាំនេះ។

២. វិធាន៦៦(១)បានផ្តល់ឱ្យភាគីនូវរយៈពេលដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ពីមានការជូនដំណឹងដើម្បីស្នើសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។

៣. នៅថ្ងៃទី៥ ខែ វិច្ឆិកា ឆ្នាំ២០០៩ មេធាវីការពារក្តី លោក នួន ជា បានដាក់សំណើមួយ "សំណើសុំឱ្យយកនូវវិធានការនីតិវិធីជាក់លាក់" (សំណើរបស់លោក នួន ជា) ដែលមេធាវីការពារបានស្នើសុំឱ្យ កសចស ជូនដំណឹងដល់ភាគីអំពីកាលបរិច្ឆេទពិតប្រាកដនៃការបញ្ចប់កិច្ចស៊ើបសួរ ដើម្បីដាក់ភស្តុតាងថ្មីៗទាំងអស់ទៅក្នុងសំណុំរឿងមុនពេលមានសេចក្តីជូនដំណឹងត្រូវបានធ្វើឡើង ហើយដើម្បីសម្រេចឱ្យបានទាន់ពេលវេលាចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់បានដោះស្រាយឱ្យបានមុនការធ្វើសេចក្តីជូនដំណឹង[1]។

៤. មេធាវីការពារក្តីសូមគាំទ្រនូវការដាក់សំណើរបស់ក្រុមមេធាវីការពារក្តីលោក នួន ជា ប៉ុន្តែសូមស្នើសុំឱ្យមានទម្រង់នៃការដោះស្រាយខុសគ្នា។

៥. មេធាវីការពារក្តីយល់ឃើញថា រយៈពេលដប់ប្រាំ (១៥) ថ្ងៃគឺមិនគ្រប់គ្រាន់ទេ ហើយស្នើសុំឱ្យមានរយៈពេលបន្ថែមទៀតរហូតដល់សែសិបប្រាំ (៤៥) ថ្ងៃ ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម។

## II. ច្បាប់ដែលពាក់ព័ន្ធ

### ២.១ មូលដ្ឋានផ្លូវច្បាប់

៦. វិធានផ្ទៃក្នុង ៦៦ (១)(ក)បានចែងថា:

> នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី។ ភាគីទាំងអស់មានរយៈពេលដប់ប្រាំ (១៥) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម។ ភាគីទាំងអស់អាចលះបង់ថេរៈវេលានេះបាន។

[1] សំណើរបស់មេធាវីការពារក្តីលោក នួន ជាស្នើសុំឱ្យយកវិធានការនីតិវិធីជាក់លាក់, ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារនេះ[មិនទាន់ត្រូវបានជូនដំណឹងនៅឡើយទេ] ។

00401581



៧. វិធានផ្ទៃក្នុង ៣៩ (៤)(ក) បានអនុញ្ញាតឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតពន្យារពេលវេលាកំណត់តាមរយៈពាក្យសុំ។

**២.២ សិទ្ធិរបស់ជនត្រូវចោទក្នុងការមានពេលវេលាគ្រប់គ្រាន់**

៨. មេធាវីការពារក្ដីយល់ឃើញថា រយៈពេលដប់ប្រាំ (១៥) ថ្ងៃដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមគឺមិនគ្រប់គ្រាន់ ហើយនិងធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងថែមទៀតប្រសិនបើមានភស្តុតាងថ្មីណាមួយត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង។ ហេតុនេះ សិទ្ធិរបស់ជនត្រូវចោទក្នុង "ការមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់" ដូចដែលបានធានានៅក្នុងមាត្រា ១៤ (៣)(ខ) នៃអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ(ICCPR)នឹងត្រូវបានគេរំលោភបំពាន។

**III. សេចក្ដីសង្ខេបនៃអង្គហេតុដែលពាក់ព័ន្ធ**

៩. សំរាប់អង្គហេតុដែលពាក់ព័ន្ធនេះ មេធាវីការពារក្ដីសូមលើកយកកថាខណ្ឌទី ២០-៤៧ នៃសំណើរបស់ក្រុមមេធាវីលោក នួន ជា ដែលបានបរិយាយយ៉ាងពិស្ដារអំពីបញ្ហាពិតប្រាកដនៅជុំវិញការបិទការស៊ើបសួរ និងរយៈពេលដប់ប្រាំ (១៥) ថ្ងៃសំរាប់ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម ហើយដែលមេធាវីការពារក្ដីសូមយកតាមនូវចំណុចដែលបានលើកឡើងខាងលើនេះ។

**IV. អំណះអំណាង**

១០. មេធាវីការពារក្ដីយល់ឃើញថារយៈពេលដប់ប្រាំ (១៥) ថ្ងៃនៅក្នុងវិធានផ្ទៃក្នុង ៦៦ (១) មិនបានអនុញ្ញាតឱ្យមេធាវីការពារក្ដីវាយតម្លៃឱ្យបានត្រឹមត្រូវចំពោះភស្តុតាងថ្មីៗ ដែលនឹងត្រូវដាក់ចូលនៅក្នុងសំណុំរឿងរហូតដល់មានការចេញសេចក្ដីជូនដំណឹងនៃវិធានផ្ទៃក្នុង ៦៦ និង ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតនោះ។ ហេតុនេះ វាពិតជារំលោភទៅលើសិទ្ធិរបស់ជនត្រូវចោទក្នុងការមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់នៅក្នុងការរៀបចំការពារក្ដីរបស់គាត់ដូចដែលបានធានានៅក្នុងមាត្រា ១៤ (៣)(ខ) នៃ អនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)។

១១. នៅពេលដែល កសចស បានកំណត់ "ខែធ្នូឆ្នាំ២០០៩"ជាខែដែលខ្លួនមានបំណងជូនដំណឹងដល់គ្រប់ភាគីអំពីការបិទការស៊ើបសួររបស់ខ្លួននោះ កសចស មិនបានកំណត់ថាតើពេលវេលានេះនឹងចាប់ផ្ដើមនៅដើមខែធ្នូ ឬ ចុងខែធ្នូនោះនៅឡើយទេ។ ដោយហេតុថា ពេលវេលាចុងក្រោយនៃខែនោះត្រូវបានគិតថាជាពេលវេលាឈប់សំរាក ដូច្នេះវាមានសារៈសំខាន់ណាស់សំរាប់មេធាវីការពារក្ដីដើម្បីឱ្យបានដឹងឱ្យបានឆាប់ដែលអាចធ្វើទៅបានចំពោះពេលវេលាពិតប្រាកដនៃការជូនដំណឹង

បែបហ្នឹង ជាពិសេសចំពោះថ្ងៃឈប់សំរាកដែលអាចមាននៅក្នុងកំឡុងពេលដប់ប្រាំ(១៥)ថ្ងៃដែលត្រូវរាប់គឺតក្នុងរយៈពេលដប់ប្រាំថ្ងៃ(១៥)ទាំងនោះ។

១២. មេធាវីការពារក្តីយល់ឃើញថារយៈពេលដប់ប្រាំ (១៥)ថ្ងៃ ដែលបានផ្តល់ឲ្យតាមរយៈវិធានផ្ទៃក្នុង ៦៦(១) គឺមិនគ្រប់គ្រាន់ទេសំរាប់ភាគីទាំងឡាយ ហើយមេធាវីការពារក្តីសូមស្នើឲ្យ កសចស អនុញ្ញាតឲ្យភាគីទាំងឡាយដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមនៅក្នុងរយៈពេល សែសិបប្រាំ (៤៥) ថ្ងៃជំនួសវិធាន ៦៦ ស្តីពីការជូនដំណឹង នោះវិញ។

## V. សំណូមពរ

១៣. សំរាប់ហេតុផលទាំងអស់នេះ, មេធាវីការពារក្តីសូមស្នើឲ្យ កសចស ធ្វើដូចខាងក្រោម៖

(i) ជូនដំណឹងដល់គ្រប់ភាគីអំពីកាលបរិច្ឆេទពិតប្រាកដនៃការជូនដំណឹងរបស់ខ្លួន។

(ii) ដាក់ចូលបន្ថែមនូវព័តមានថ្មីៗដែលប្រមូលបានទៅក្នុងសំណុំរឿងនាពេលវេលាដ៏សមគួរបំផុត ហើយនិង,

(iii) ពន្យារពេលវេលាកំណត់ចំនួនដប់ប្រាំ(១៥)ថ្ងៃដែលបានផ្តល់ឲ្យនៅក្នុងវិធានផ្ទៃក្នុង ៦៦(១) ឲ្យបានសែសិបប្រាំ (៤៥)ថ្ងៃ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវីការពារក្តី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អ្នកស្រី អៀង ធីរិទ្ធ | ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ | លោក ផាត់ ពៅស៊ាង<br>Diana ELLIS, QC | រាជធានីភ្នំពេញ | [signatures] |